## ៩. ការពិគ្រោះយោបល់សាធារណៈ

១៤៥. ការពិគ្រោះយោបល់សាធារណៈលើកដំបូងជាមួយថ្នាក់ដឹកនាំខេត្ត ស្រុក មន្ទីរ/ស្ថាប័ន ឃុំ ភូមិ និងប្រជាជនសហគមន៍ដែលពាក់ព័ន្ធ បានរៀបចំធ្វើឡើងនៅក្នុងដំណើរការរៀបចំរបាយការណ៍ ដើម្បីធ្វើការព្យាករណ៍អំពីផលប៉ះពាល់ និងផ្តល់នូវអនុសាសន៍ដើម្បីផ្តល់ប្រយោជន៍ជាមូលដ្ឋានក្នុងការសំរេចចិត្តថាតើគួរគ្រប់គ្រងតាមដានត្រួតពិនិត្យវាយតម្លៃការអនុវត្តន៍គំរោងរបស់ក្រុមហ៊ុនរ៉ែ Ilmenite យ៉ាងដូចម្តេច ។ ថ្នាក់ដឹកនាំខេត្ត ស្រុក មន្ទីរ/ស្ថាប័ន ឃុំ ភូមិ ដែលបានចូលរួមក្នុងដំណើរការរៀបចំ របាយការណ៍ បានទទួលការពន្យល់អំពីគំរោងដោយសង្ខេប ។ សមាសភាពដែលបានចូលរួមយោបល់មាន: អភិបាលរងខេត្តកោះកុង អគ្គលេខាធិការសាលាខេត្ត នាយខុទ្ទកាល័យស្តីទីសាលាខេត្ត ប្រធានមន្ទីរឧស្សាហកម្មរ៉ែ និងថាមពលខេត្តកោះកុង ប្រធានមន្ទីរកសិកម្ម ខេត្តកោះកុង ប្រធានមន្ទីរបរិស្ថានខេត្តកោះកុង នាយខ័ណ្ឌ រដ្ឋបាលព្រៃឈើខេត្តកោះកុង អភិបាលស្រុកស្រែអំបិល អភិបាលស្រុកថ្មបាំង និងអង្គការសង្គមស៊ីវិលដូចមានឈ្មោះនៅក្នុងតារាងឧបសម្ពន្ធ័(៩-១)និងកំណត់ហេតុរបាយការណ៍(សូមអាននៅទំព័រទី ១២៨-១៤៣)ដែលបានធ្វើឡើងនៅថ្ងៃ ទី ១៦ ខែ តុលា ឆ្នាំ ២០០៩។ ហើយការជួបពិភាក្សាផ្ទាល់ជាមួយក្រុមប្រឹក្សាស្រុក មេឃុំ សមាជិកឃុំ ស្មៀនឃុំ ក្រុមប្រឹក្សាអភិវឌ្ឍន៍ឃុំ មេភូមិ និងអនុភូមិ ដែលរស់នៅក្នុងតំបន់គំរោងជាច្រើន នាក់ ដូចមានឈ្មោះ (តារាងទី៩-២) និងរូបថតនៅក្នុងឧបសម្ព័ន្ធ ៩-៣ ។

**របាយការណ៍សង្ខេបនៃការពិគ្រោះយោបល់សាធារណៈជាមួយសហគមន៍មូលដ្ឋាន ស្តីពីការវាយតំលៃហេតុប៉ះពាល់បរិស្ថាននិងសង្គមដំបូង**

**របាយប្រជាជន**

១៤៦. ក្រុមការងារធ្វើការសិក្សាវាយតំលៃអំពីស្ថានភាពជីវភាពរស់នៅ របស់ប្រជាពលរដ្ឋក្នុងតំបន់ដែលក្រុមហ៊ុន **សំណាង់រ៉ែត្បូងថ្ម (Samnang Rea Thbong Thmor Co., Ltd.)** បានស្នើសុំ ដែលមានទីតាំងស្ថិតនៅជាប់ឃុំថ្មដូនពៅ និងឃុំជំនាប់ ស្រុកថ្មបាំង និងក្នុងឃុំជីខលើ ស្រុកស្រែអំបិល ខេត្តកោះកុង ។ ឃុំថ្មដូនពៅ មានប្រជាជនសរុប ចំនួន**១០៧**គ្រួសារ ស្មើនឹង**៤១៣**នាក់ ក្នុងនោះមានស្ត្រីចំនួន**២០៥**នាក់ រស់នៅក្នុងភូមិចំនួន ០២ គឺ: (១) ភូមិព្រែកស្វាយ មានប្រជាជនរស់នៅចំនួន ៦៥គ្រួសារ សរុប២៣២នាក់ ក្នុងនោះស្ត្រីមាន ១១៥នាក់ (២) ភូមិកោះ មានប្រជាជនចំនួន ៤២គ្រួសារ សរុប១៨១នាក់ ស្ត្រីមាន៥២១នាក់ និងឃុំជំនាប់ មានប្រជាជន **៧៤**គ្រួសារ មនុស្សសរុបចំនួន **៣១៦**នាក់ ស្ត្រីមាន**១៥៧**នាក់ ដែលរស់នៅក្នុងភូមិ ចំនួន២: (១) ភូមិច្រកឫស្សី មានប្រជាជន ចំនួន ៣៦គ្រួសារ មនុស្សសរុប ១៤៩នាក់ ក្នុងនោះស្ត្រីមាន ៧០នាក់ (២)

Draft

ភូមិជំនាប់ មានប្រជាជន ចំនួន ៣៨គ្រួសារ សរុប១៦៨នាក់ ក្នុងនោះស្ត្រី មាន៨៧នាក់។ ចំណែកឯ ឃុំជីខលើ មានប្រជាជនចំនួន **១៤១៩**គ្រួសារ ស្មើនឹង **៣៤៤៧**នាក់ ក្នុងនោះស្ត្រី **១៧០៩**នាក់ រស់នៅក្នុងភូមិចំនួន ៤គឺ (១) ភូមិជីខ មានប្រជាជន ១៩០គ្រួសារ ស្មើនឹង ៩៧១នាក់ ក្នុងនោះស្ត្រី ចំនួន៤៩៤នាក់ (២) ភូមិឈូក មានប្រជាជន ២២៨គ្រួសារ ស្មើនឹង១២២៨នាក់ ក្នុងនោះស្ត្រីចំនួន ៥៩៤នាក់ (៣) ភូមិតានី មានប្រជាជន ១៨១ គ្រួសារ ស្មើនឹង៨៤៦នាក់ ក្នុងនោះស្ត្រីចំនួន៤៣៤នាក់ (៤) ភូមិត្រពាំងកណ្តោល មានប្រជាជន៨២ គ្រួសារ ស្មើនឹង ៤០៦នាក់ ក្នុងនោះស្ត្រីចំនួន១៨៧នាក់ (ស្ថិតិប្រជាជនរបស់ឃុំជីខលើ ឆ្នាំ២០០៧)។ សូមបញ្ជាក់ផងដែរ ទីតាំងស្នើសុំធ្វើអាជីវកម្មរ៉ែនេះនៅក្នុងទឹកដីស្រុកថ្មបាំង និងស្រុកស្រែអំបិលមែន ដែលមានឃុំថ្មដូនពៅ ឃុំជំនាប់ និងឃុំជីខលើ ប៉ុន្តែវាមិនពាក់ព័ន្ធ និងការរស់នៅក្នុងការប្រកបរបរចិញ្ចឹមជីវិតរបស់ពួកគាត់ទេ គឺស្ថិតនៅឆ្ងាយ១៦-២០គ.ម ពីភូមិ។

**ស្ថិតិប្រជាពលរដ្ឋឃុំថ្មដូនពៅ និងឃុំជំនាប់ ស្រុកថ្មបាំង ឆ្នាំ ២០០៩**

| ល.រ | ឈ្មោះភូមិ | ចំនួនគ្រួសារ | ចំនួនមនុស្ស | | អាយុ១៨ឆ្នាំឡើង | |
|---|---|---|---|---|---|---|
| | | | សរុប | ស្រី | សរុប | ស្រី |
| **ឃុំថ្មដូនពៅ** | | | | | | |
| ១ | ព្រែកស្វាយ | ៦៥ | ២៣២ | ១១៥ | ១៣៨ | ៧៦ |
| ២ | កោះ | ៤២ | ១៨១ | ៩០ | ១០៨ | ៤៦ |
| | **សរុប** | **១០៧** | **៤១៣** | **២០៥** | **២៤៦** | **១២២** |
| **ឃុំជំនាប់** | | | | | | |
| ១ | ច្រកឫស្សី | ៣៦ | ១៤៩ | ៧០ | ៨៣ | ៣៥ |
| ២ | ជំនាប់ | ៣៨ | ១៦៨ | ៨៧ | ៨៧ | ៤៥ |
| | **សរុប** | **៧៤** | **៣១៦** | **១៥៧** | **១៧០** | **៨០** |

**ស្ថិតិប្រជាពលរដ្ឋឃុំជីខលើ ស្រុកស្រែអំបិល ឆ្នាំ ២០០៧**

| ល.រ | ឈ្មោះភូមិ | ចំនួនគ្រួសារ | ចំនួនមនុស្ស | | អាយុ១៨ឆ្នាំឡើង | |
|---|---|---|---|---|---|---|
| | | | សរុប | ស្រី | សរុប | ស្រី |
| ១ | ជីខ | ១៩០ | ៩៧១ | ៤៩៤ | ៤៨៩ | ១៥០ |
| ២ | ឈូក | ២២៨ | ១២២៨ | ៥៩៤ | ៥៧២ | ២២០ |
| ៣ | តានី | ១៨១ | ៨៤៦ | ៤៣៤ | ៣៦៥ | ១៩៧ |



Draft

| | | | | | | |
|---|---|---|---|---|---|---|
| ៤ | ត្រពាំងកណ្តាល | ៨២ | ៤០៦ | ១៨៧ | ១៧៤ | ៩៥ |
| | សរុប | ៦៨១ | ៣៤៥១ | ១៧០៩ | ១៦០០ | ៦៦២ |

**១៤៧.** លំនាំនៃការតាំងទីលំនៅរបស់ប្រជាជនមានលក្ខណៈជាជួរៗ នៅតាមដងផ្លូវដែលក្រាលក្រួសក្រហម ចេញពីទីរួមស្រុក មួយចំនួនទៀតជាលក្ខណៈប្រមូលផ្តុំនៅតាមភូមិ ដោយតាំងទីលំនៅតាមដងផ្លូវលំនៅក្នុងភូមិ និងគ្រួសារខ្លះទៀតបានធ្វើការតាំងទីលំនៅតាមជើងភ្នំ(ជាដីចំការដែលបានកាប់រឿន) និងតាមដងស្ទឹង។ នៅពេល ដែលក្រុមការងារយើងចុះទៅសំភាសន៍ គឺធ្វើតែថ្នាក់ដឹកនាំភូមិ ឃុំ ស្រុក តែប៉ុណ្ណោះ ជាពិសេសនៅក្នុងឃុំថ្មដូនពៅ ឃុំជំនាប់ ស្រុកថ្មបាំង និងឃុំជីខលើស្រុកស្រែអំបិល ខេត្តកោះកុង។

**១៤៨.** លទ្ធផលនៃការពិគ្រោះយោបល់ជាមួយនឹងតំណាងប្រជាពលរដ្ឋ(អាជ្ញាធរ)បានបញ្ជាក់ថា ការរស់នៅជីវភាព របស់ពួកគាត់ជួបនូវការលំបាកដោយកត្តាផ្សេងៗជាច្រើនដូចជា បញ្ហាផលិតផលដំណាំដែលដាំបានលក់មិនបាន ថ្លៃ ដោយសារផ្លូវគមនាគមន៍មានការលំបាកខ្លាំង ហើយទំនិញនាំចូលទៅក្នុងតំបន់មានតំលៃថ្លៃ នៅពេល ធ្វើដំណើរទៅទីផ្សារចំណាយពេលយូរថ្ងៃ ហើយតម្រូវអោយពួកគាត់ត្រូវចំណាយប្រាក់ច្រើន ដើម្បីទៅទិញ ទំនិញទាំងនោះ។(តាមការសាកសួរលោកមេឃុំ ដែលបានធ្វើបទសំភាសន៍)។

## លក្ខណៈប្រជាសាស្ត្រ

**១៤៩.** យោងលើការអង្កេតជាក់ស្តែង និងពត៌មានដែលទទួលបានពីមូលដ្ឋានបង្ហាញឱ្យដឹងថា ប្រជាជនរស់នៅ ទីនោះជាជនជាតិខ្មែរសុទ្ធសាធ ប្រកាន់ខ្ជាប់នូវប្រពៃណីទំនៀមទំលាប់ និងកាន់ ព្រះពុទ្ធសាសនាយ៉ាងខ្ជាប់ខ្ជួន។ ហើយមុខរបរចិញ្ចឹមជីវិតរបស់ពួកគាត់ គឺធ្វើចំការ៩៥ភាគរយ និងធ្វើស្រែ៥ភាគរយ រីឯការនេសាទជាមុខរបរ បន្ទាប់បន្សំ នេសាទជាលក្ខណៈគ្រួសារសំរាប់ហូបតែប៉ុណ្ណោះ។ ឃុំថ្មដូនពៅ និងឃុំជំនាប់ស្ថិតនៅចម្ងាយប្រមាណ ៣០-៣៥គ.ម ពីទីរួមស្រុក និង ១០៥គ.ម ដល់ខេត្ត។ ចំណែកឯឃុំ ជីខលើវិញស្ថិតនៅចម្ងាយ ប្រមាណ១២គ.ម ពីស្រុក និង ១២៨គ.ម ពីទីរួមខេត្ត។

**១៥០.** ចំពោះជនបង្គោល ឬអ្នកមានតួនាទីសំខាន់នៅក្នុងការទ្រទ្រង់ជីវភាពគ្រួសារនៅតំបន់នេះ ក្រុមការ ងារសង្កេតឃើញថាភាគច្រើនជាបុរស។ ចំណែកលទ្ធភាពទទួលការអប់រំរបស់មេគ្រួសារនៅក្នុងតំបន់នេះវិញ (តំបន់ដែលពាក់ព័ន្ធនឹងទីតាំងស្នើសុំធ្វើអាជីវកម្មរបស់ក្រុមហ៊ុន) គឺនៅមានកំរិតទាប (ត្រឹមថ្នាក់ទី១២-៨ចាស់) បើប្រៀបធៀបនឹងលទ្ធភាពដែលមេគ្រួសារនៅតាមទីក្រុង និងតាមទីប្រជុំជនធំៗបានទទួល។ ប៉ុន្តែនាពេល បច្ចុប្បន្ន វិស័យអប់រំនៅក្នុងតំបន់ដែលពាក់ព័ន្ធនេះគឺមានការរីកចំរើនយ៉ាងច្រើន ហើយកុមារស្ទើរតែទាំងអស់ បានចូលរៀន ព្រោះមានសាលារៀននៅគ្រប់ភូមិទាំងអស់។



Draft

**១៥១.** ប្រជាពលរដ្ឋនៅទីនោះមានជំនឿលើព្រះពុទ្ធសាសនា និងបានប្រកាន់ខ្ជាប់នូវប្រពៃណីទំនៀមទំលាប់ខ្មែរ។ យើងសង្កេតឃើញមានពិធីបុណ្យជាច្រើនដូចជាបុណ្យ ភ្ជុំបិណ្ឌ ចូលឆ្នាំ មាឃបូជា ពិសាខបូជា ជាដើម គេតែងតែមកជួបជុំគ្នានៅវត្ត ហើយនៅតំបន់នោះមានវត្តស្ទើរគ្រប់ឃុំ។

**ស្ថានភាពផ្ទះសម្បែង និងទ្រព្យសម្បត្តិរបស់គ្រួសារ**

**១០៦.** តាមការចុះសិក្សារបស់ក្រុមការងារបាន បង្ហាញថា ប្រជាជនរស់នៅក្នុងឃុំថ្មដូនពៅ ឃុំជំនាប់ និងឃុំជីខលើ ភាគច្រើនមានជីវភាពមធ្យមអាចឱ្យពួកគាត់ មានលទ្ធភាព សង់លំនៅដ្ឋានសមស្របអាចជ្រកកោនបាន។ ផ្ទះរបស់ពួកគាត់ភាគច្រើនប្រក់ស្លឹក៧៩% និងស័ង្កសី២០% ហ្វីប្រូស៊ីម៉ង់ត៍១%(ឃុំថ្មដូនពៅ និងឃុំជំនាប់)។ ចំពោះឃុំជីខលើវិញមានប្រជាពលរដ្ឋសរុប ៦៨១គ្រួសារ មានផ្ទះប្រក់ស្បូវប្រមាណ ៤០% ផ្ទះប្រក់សង្កសី មាន៥៥% និងផ្ទះប្រក់ក្បឿងតែ៥%ប៉ុណ្ណោះ។ ហើយផ្ទះទាំងនោះសង់ ផុតពីដី ១.៥-២ម មានទំហំ ៣០-៤០ម$^{២}$ ឬសង់ផ្ទាល់ដី ដែលការសង់លំនៅដ្ឋាន ប្រែប្រួលទៅតាមលទ្ធភាព និងចំនួនសមាជិកនៃគ្រួសារនិមួយៗ។

**១៥២.** ចំណែកឯសំភារៈសម្រាប់ដំណើរការផលិតកម្មកសិកម្ម និងមធ្យោបាយធ្វើដំណើរវិញ យើងឃើញមានដូចជាគោយន្តភ្ជួរស្រែ៦គ្រឿង ម៉ាស៊ីនបោកស្រូវ ៣គ្រឿង រទេះគោ៥គ្រឿង ចំពោះមធ្យោបាយធ្វើដំណើរវិញមានម៉ូតូ២៨គ្រឿង កង់២៣គ្រឿង ហើយក្នុងនោះផងដែរ យើងឃើញមានការចិញ្ចឹមសត្វ ដូចជាក្របីមាន ៣០គ្រួសារ ជ្រូក ៤៥គ្រួសារ មាន់ ៧៤គ្រួសារ។ ចំណែកឯឃុំជីខលើវិញ តាមការចុះសិក្សាអង្កេត នឹងសាកសួរពីមេភូមិ និងប្រជាជនក្នុងតំបន់បានបង្ហាញថា ប្រជាពលរដ្ឋយើងរស់នៅតាមបណ្តោយផ្លូវជាតិលេខ៤៨ ហើយជាមធ្យោបាយធ្វើដំណើរទៅមក ពួកគាត់ប្រើប្រាស់កង់-ម៉ូតូ និងរថយន្ត ដោយឡែកពេលចូលព្រៃនិង ទៅធ្វើស្រែចំការ ពួកគាត់ប្រើប្រាស់រទេះគោ-ក្របី ឬធ្វើដំណើរថ្មើរជើងតែម្តង។ នៅក្នុងឃុំជីខលើ មានកង់ចំនួន២១០គ្រឿង ម៉ូតូចំនួន ២១៤ គ្រឿង។ តាមស្ថិតិរបស់មេឃុំជីខលើ បានបង្ហាញថា នៅក្នុងឃុំ មានរទេះគោចំនួន២៧៦គ្រឿង គោយន្តចំនួន ២៦គ្រឿង រថយន្តដឹកទំនិញ២គ្រឿង និងមានម៉ាស៊ីនកិនស្រូវចំនួន ៧គ្រឿង។

**១៥៣.** ចំពោះការប្រើប្រាស់ និងការកាន់កាប់ដីធ្លី ពួកគាត់មានបង្កាន់ដៃបញ្ជាក់ពីឃុំត្រឹមត្រូវ ហើយពួកគាត់មានដីលំនៅដ្ឋានជាមធ្យមប្រមាណគឺ ៨០០ម$^{២}$ ក្នុងមួយគ្រួសារ ដីចំការប្រមាណ ២-៣ ហិកតា ក្នុងមួយគ្រួសារមួយចំនួនទៀតមានរហូតដល់៥ ហិកតា។

**១៥៤.** ក្រៅពីការចិញ្ចឹមគោ-ក្របីប្រើប្រាស់ជាកំលាំងអូសទាញ ប្រជាជននៅមានចិញ្ចឹមសត្វជាលក្ខណៈគ្រួសារសំរាប់ទ្រទ្រង់ជីវភាពគ្រួសាររបស់ពួកគាត់បន្ថែមទៀត។ ជាក់ស្តែង ក្នុងភូមិស្ទឹងថ្មីទាំងមូលមានប្រជាជនប្រមាណ៥០គ្រួសារចិញ្ចឹមជ្រូក ក្នុងនោះមានប្រជាជន៣គ្រួសារចិញ្ចឹមជ្រូកពី៣-៤ក្បាល។ ប្រជាជន

២៣១គ្រួសារមានចិញ្ចឹមមាន់ ក្នុងនោះ៥៧គ្រួសារចិញ្ចឹមមាន់ពី៣ក្បាលឡើងទៅ (ទិន្នន័យស្រង់ពីស្ថិតិភូមិស្ទឹងថ្មីឆ្នាំ២០០៦)។ ជ្រូករស់អាចលក់១គីឡូក្រាមតំលៃ ៤០០០រៀល មាន់តំលៃ៧០០០រៀលក្នុង១គីឡូក្រាម ទាសំពៅមួយលក់បានតំលៃ៧០០០រៀល រីឯទាកាប៉ាមួយតំលៃជាមធ្យម១៥០០០រៀល (ទិន្នន័យបានមកពីការសំភាសន៏ផ្ទាល់មាត់ជាមួយប្រជាជននៅក្នុងភូមិ)។ ប្រជាជននៅក្នុងភូមិក៏ដូចជាទូទាំងឃុំដែរ គឺពុំមានអ្នកចំណាកស្រុកដើម្បីស៊ីឈ្នួលគេទេ មានតែមនុស្សពីខាង ក្រៅចូលមករកការងារធ្វើនៅទីនេះវិញ។

**សេវាសាធារណៈ**

**១៥៥.** គួរបញ្ជាក់ថា លទ្ធភាពនៃការប្រើប្រាស់សេវាសាធារណៈ (គមនាគមន៍ ការផ្គត់ផ្គង់ទឹកស្អាត អគ្គិសនី អប់រំ និង សុខាភិបាល) នៅក្នុងតំបន់ដែលពាក់ព័ន្ធនឹងទីតាំងស្នើសុំដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុនអាជីវកម្មរ៉ែនៅមានកំរិតទាបនៅឡើយ។ ភាពខ្វះខាតនៃសេវាសាធារណៈទាំងអស់នេះបានបង្កការលំបាកគ្រប់បែបយ៉ាងចំពោះពួកគាត់នៅទីនោះ ហើយវាក៏ជាបន្ទុកដ៏ធ្ងន់ធ្ងរសំរាប់រាជរដ្ឋាភិបាលផងដែរ។

**១៥៦.** ការប្រើប្រាស់ផ្លូវគមនាគមន៍ទៅកាន់តំបន់ស្នើសុំដីសម្បទានធ្វើអាជីវកម្មរ៉ែរបស់ក្រុមហ៊ុនពុំបានទទួលនូវការផ្គត់ផ្គង់សេវាទាំងនេះទេ ពីព្រោះតំបន់នេះជាតំបន់នៅឆ្ងាយ មានផ្លូវធ្វើដំណើរពិបាក(ផ្លូវក្រួសក្រហមឡើងចុះជាតំបន់ភ្នំ) ហើយដាច់ស្រយាលពីខេត្ត និងទីរួមស្រុក ដែលពុំអាច ទទួលបាននូវសេវាទាំងនោះឡើយ។ ចំណែកឯឃុំជីខលើ ផ្លូវគមនាគមន៍ដ៏សំខាន់សំរាប់ប្រជាពលរដ្ឋ ឃុំជីខលើ ធ្វើដំណើរ និងដឹកជញ្ជូនផ្សេងៗ គឺផ្លូវជាតិលេខ៤៨។

**១៥៧.** ក្នុងតំបន់ដែលយើងបានចុះធ្វើការសិក្សាវាយតម្លៃ គេឃើញមានវត្តមានអង្គការមួយចំនួនបានចុះមកបណ្តុះបណ្តាល និងផ្តល់សេវាកម្មផ្សេងៗ។ ដោយឡែក ក្នុងឃុំថ្មដូនពៅ និងឃុំជំនាប់មានអង្គការ FUNA & FLORA International និងអង្គការ CONSEVATION *International* អភិរក្សសត្វព្រៃ ក្រពើភ្នំ និងត្រីនាគ និងអង្គការសង្គ្រោះសត្វព្រៃ(SCW)។ ចំណែកឃុំជីខលើវិញមានអង្គការ Wild Aid ជួយអភិរក្សសត្វព្រៃលិចទឹក និងអង្គការ RAC ផ្តល់សេវាសុខភាព និងអង្គការហ្វីកត័រ ជួយអណ្តូងទឹក។

**១៥៨.** ទោះបីជាមានវត្តមានអង្គការចូលរួមជួយសហគមន៏ក៏ដោយ ក៏យើងនៅតែសង្កេតឃើញថា លទ្ធភាពប្រើប្រាស់ទឹកស្អាតរបស់ប្រជាជននៅមានកំរិតទាបនៅឡើយ។ ជាក់ស្តែង នៅក្នុងឃុំជីខលើ ពួកគាត់ប្រើទឹកអណ្តូងជីកដៃ និងទឹកអណ្តូងស្នប់ (មានតិចតួច) សំរាប់បរិភោគតែប៉ុណ្ណោះ។ យើងសង្កេតឃើញថា ប្រជាពលរដ្ឋក្នុងតំបន់នេះមានការខ្វះខាតទឹកសំរាប់ប្រើប្រាស់ជាខ្លាំង ព្រោះនៅរដូវប្រាំង ប្រភពទឹកដែលមាននៅទីនេះត្រូវបានរីងស្ងួត និងមានទឹកល្អក់ខ្លាំងនៅរដូវវស្សាប្រើប្រាស់ពុំបានឡើយ។ អាស្រ័យហេតុដូចនេះ ហើយបានជាយើងឃើញមានមនុស្សឈឺច្រើន ជាពិសេសចំពោះកុមារតូចៗ ដែលបណ្តាលមកពីការហូបទឹកមិនស្អាតគ្មាន



Draft

អនាម័យ ដោយមិនបានដាំឱ្យពុះសម្លាប់មេរោគ មុននឹងយកទៅប្រើប្រាស់។ ចំណែកឯឃុំថ្មដូនពៅ និង ឃុំជំនាប់វិញពួកគាត់ប្រើប្រាស់ទឹកអណ្តូងស្នប់ និងអណ្តូងជីកដៃ ឯរដូវវស្សាត្រង់ទឹកភ្លៀងប្រើជំនួសទឹកអណ្តូង

**១៥៩.** ជាទូទៅ ការប្រើប្រាស់ថាមពលក្នុងការបំភ្លឺនៅពេលយប់របស់ប្រជាជននៅក្នុងតំបន់ធ្វើអាជីវកម្មរ៉ែរបស់ក្រុមហ៊ុនមានកំរិតទាបនៅឡើយ។ តាមការអង្កេតជាក់ស្តែងចំពោះការប្រើប្រាស់បណ្តាញអគ្គិសនី នៅក្នុងតំបន់ទាំងពីរនេះពុំទាន់ មានការផ្គត់ផ្គង់បណ្តាញអគ្គិសនីនៅឡើយទេ ដោយសារតែតំបន់នៅឆ្ងាយពីទីប្រជុំជន ហើយប្រជាពលរដ្ឋពុំមាន លទ្ធភាពគ្រប់គ្រាន់សំរាប់ចំណាយ ហេតុដូចនេះហើយបានជាយើងឃើញមានតែការប្រើប្រាស់ម៉ាស៊ីនភ្លើង ប្រមាណ ១០-១៥គ្រួសារ ស្មើ១១ភាគរយ ក្រៅពីនោះប្រើប្រាស់ចន្លុះ និងចង្កៀងប្រេងមាស៊ូតប្រមាណ៨៥ភាគរយ និង៤ភាគរយប្រើប្រាស់អាគុយ (ឃុំថ្មដូនពៅ និងឃុំជំនាប់)។ ចំណែកឯឃុំជីខលើប្រើប្រាស់អាគុយ ៨៥% និង ១៥% ប្រើប្រាស់ចង្កៀងប្រេងកាត មានគ្រួសារប្រមាណ៦០ភាគរយមានវិទ្យុ និង១៥ភាគរយមានទូរទស្សន៍ប្រើប្រាស់ ជាហេតុធ្វើឱ្យពួកគាត់អាចយល់ដឹងពីព្រឹត្តិការណ៍ថ្មីៗរបស់ជាតិ និងពិភពលោកខ្លះៗផងដែរ។ ចំពោះការចំអិនអាហារវិញពួកគាត់ប្រើអុសដែលនៅក្បែរភូមិខ្លះទៀតប្រើធ្យូង និងមួយចំនួនតូចប្រើហ្គាស។

**១៦០.** វិស័យអប់រំសិក្សាធិការវិញ លទ្ធផលនៃការសិក្សាបង្ហាញថា នៅក្នុងតំបន់ទីតាំងស្នើសុំធ្វើអាជីវកម្មនៃស្រុកទាំងពីរ គឺឃុំថ្មដូនពៅ និងឃុំជំនាប់ ពុំមានអនុវិទ្យាល័យ និងវិទ្យាល័យទេគឺមានតែសាលាបឋមសិក្សាត្រឹមថ្នាក់ទី១ ដល់ទី៤ បើចង់បន្តការសិក្សា ត្រូវទៅរៀននៅស្រុកថ្មបាំង ឬនៅខេត្តតែម្តង៧០គ.ម។ ចំណែកឯឃុំជីខលើវិញក្នុងភូមិនីមួយៗ មានសាលាបឋមសិក្សា ១ខ្នង និងមានអនុវិទ្យាល័យ១នៅក្នុងឃុំ ស្ថិតនៅក្នុងភូមិជីខ ដែលបង្កលក្ខណៈងាយស្រួលឱ្យសិស្សានុសិស្ស នៅក្នុងភូមិត្រពាំងកណ្តោល តានី និងឈូក មករៀនបាន។ ចំណែកឯសិស្សដែលបន្តការសិក្សានៅវិទ្យាល័យ ត្រូវទៅសិក្សានៅទីរួមស្រុកស្រែអំបិល ដែលមានចម្ងាយផ្លូវប្រមាណជា ១២-១៤ គ.ម ឬទៅទីរួមខេត្តកោះកុង ដែលមានចំងាយ១៤៥គីឡូម៉ែត្រពីឃុំ។

**១៦១.** ចំពោះសេវាសុខភាពនៅក្នុងឃុំ ថ្មដូនពៅ និងឃុំជំនាប់ ពុំមានប៉ុស្តិ៍សុខភាពតាមភូមិ និងឃុំទេគឺមានតែសេវាសុខភាពគ្រូពេទ្យស្ម័គ្រចិត្តតាមភូមិ ពុំមានថ្នាំសង្កូវគ្រប់គ្រាន់សំរាប់បំរើឱ្យសុខភាពប្រជាពលរដ្ឋនៅឡើយ បើមាននរណាម្នាក់មានជម្ងឺត្រូវធ្វើដំណើរតាមម៉ូតូ ឬសែងតាមផ្លូវឡើងចុះ និងឆ្លងកាត់អូរដើម្បីឱ្យដល់ស្រុកដែលមានចម្ងាយផ្លូវប្រមាណ ៣៥គ.ម ប៉ុន្តែផ្លូវលំបាកខ្លាំង។ រីឯឃុំជីខលើវិញ តាមការសិក្សាបានបង្ហាញឱ្យឃើញថា ក្នុងឃុំក៏ពុំមានប៉ុស្តិ៍សុខភាពដែរ នៅពេលមានមនុស្សឈឺដឹកយកទៅមន្ទីរពេទ្យបង្អែកស្រុក ឬទៅខេត្តតែម្តង។

Draft

### ប្រភពធនធានធម្មជាតិ និងលទ្ធភាពនៃការទទួលយកធនធានធម្មជាតិ

**១៦២.** ធនធានព្រៃឈើដែលប្រជាជនទទួលយកបានមានដូចជា ឈើឧស ឈើស្នាច់សំរាប់ធ្វើបង្គោលរបង ឈើក្រាក់ និងការនេសាទត្រីនៅតាមព្រែកអូរនិងបឹងនៅក្បែរភូមិ ។ តាមការសិក្សា យើងទទួលបានថាអនុផលព្រៃឈើមានការធ្លាក់ចុះយ៉ាងខ្លាំងក្នុងរយៈពេល២ទស្សវត្សចុងក្រោយនេះ ដោយសារការកាប់ព្រៃយ៉ាងអាណាធិបតេយ្យរបស់ឈ្មួញទុច្ចរិត ហើយបច្ចុប្បន្ននេះឈើដែលមានតំលៃពាណិជ្ជកម្ម មិនមាននៅសេសសល់ច្រើនទេ (សម្តីអះអាងរបស់ប្រជាជន ដែលបានចូលរួមពិគ្រោះយោបល់) ។ ប៉ុន្តែនៅក្នុងឃុំថ្មដូនពៅ និងឃុំជំនាប់ ស្រុកថ្មបាំងនៅមានសល់ខ្លះៗតាមតបន់ភ្នំ ដោយសារមានអង្គការជាច្រើនបានសហការជាមួយនាយកដ្ឋានរដ្ឋបាលព្រៃឈើចុះមកផ្សព្វផ្សាយ និងការពារយ៉ាងតឹងរឹងនូវបទល្មើសផ្សេងៗ លើកាប់ព្រៃឈើ ការបរបាញ់សត្វព្រៃ ការនេសាទក្រពើភ្នំ និងត្រីនាគ ។ល ។

### ប្រភពចំណូលសំខាន់របស់គ្រួសារ

**១៦៣.** តាមការចុះអង្កេតជាក់ស្តែង និងការសាកសួរអាជ្ញាធរដែររស់នៅតំបន់នោះបានឱ្យដឹងថា ប្រជាពលរដ្ឋនៅក្នុងភូមិទាំងនេះភាគច្រើនប្រកបរបរធ្វើចំការ ច្រើនជាស្រែ(ស្រូវបុកដាំ) ។ អ្នកមានដីស្រែធ្វើគឺមានចំនួនតិចតួចមិនមានគ្រប់គ្រួសារឡើយ ។ ចំពោះអ្នកធ្វើចំការវិញ ពួកគាត់ដាំដំណាំចេក ស្វាយ ល្ហុង ធុរេន សាវម៉ាវ ខ្នុរ ដូង ឪឡឹក ដែលអាចហុចផលច្រើនគួរឱ្យកត់សំគាល់ដែរ ប៉ុន្តែតំលៃថោកមិនសមទៅនឹងការ ចំណាយដើមទុនផលិត ។ ចំពោះដំណាំឪឡឹកក្នុង១ រដូវគាត់អាចលក់បានពី៣-៤លាន ។ មានគ្រួសារមួយចំនួនប្រកបមុខរបរនេសាទត្រី តាមបឹង គ្រាន់បានត្រីបន្តិចបន្តួចសំរាប់ផ្គត់ផ្គង់តំរូវការប្រចាំថ្ងៃប៉ុណ្ណោះ ។ ក្រៅពីនោះខ្លះទៀតទៅស៊ីឈ្នួល ដាំអំពៅអោយក្រុមហ៊ុន ដែលពួកគាត់ទទួលបានប្រាក់កំរៃជាមធ្យមពី១០០០០-១៥០០០រៀលក្នុងមួយថ្ងៃ ។ ប៉ុន្តែទោះបីយ៉ាងនេះក៏ដោយ ចំណូលដែលបានមកពីការធ្វើស្រែ ចំការ នេសាទត្រី និង ស៊ីឈ្នួលគេទាំងនេះ មិនអាចទ្រទ្រង់នូវជីវភាពក្នុងគ្រួសាររបស់ពួកគាត់បានទេ ពីព្រោះគ្រួសារភាគច្រើន មានសមាជិកច្រើន ហើយដីសំរាប់បង្កបង្កើនផលមានតិចតួច ។ ម្យ៉ាងទៀតដោយពួកគាត់ធ្វើស្រែអាស្រ័យ ធម្មជាតិ ម្លោះហើយទិន្នផលស្រូវដែលទទួលបានគឺទាប គិតជាមធ្យមគឺ១-២តោន ក្នុងមួយហិកតា (ក្នុង១ គីឡូក្រាម ជាមធ្យមលក់បាន ១០០០-២០០០រៀល) ។

**១៦៤.** ក្រៅពីរបរកសិកម្ម ប្រជាពលរដ្ឋនៅឃុំថ្មដូនពៅ និងឃុំជំនាប់មានចិញ្ចឹមសត្វជាលក្ខណៈគ្រួសារដើម្បីបំពេញសេចក្តីត្រូវការខាងជីវភាពប្រចាំថ្ងៃ ក្នុងនោះដែរគ្រួសារចិញ្ចឹមក្របីមាន៦០% គ្រួសារចិញ្ចឹមជ្រូក ៣៥% និងចិញ្ចឹមមាន់៩៥% ។ ប្រជាពលរដ្ឋឃុំជីខលើ បានចិញ្ចឹមចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ ដើម្បីផ្គត់ផ្គង់ ជីវភាពគ្រួសារបន្ថែមទៀត ។ តាមទិន្នន័យដែលទទួលបានពីមេឃុំបានបង្ហាញថា ការចិញ្ចឹមគោ ក្របីតិចឬច្រើនគឺអាស្រ័យទៅលើលទ្ធភាព និងកំលាំងពលកម្មនៃគ្រួសារនិមួយៗ ។ ហើយពួកគាត់អាចលក់ ក្របី១ក្បាលបាន

Draft

តំលៃពី ២.៥-៣ លានរៀល។ មានគ្រួសារចំនួន៦៥ មានលទ្ធភាពចិញ្ចឹមជ្រូកពី១-៣ក្បាល ប្រជាពលរដ្ឋ ៤១គ្រួសារមានលទ្ធភាពចិញ្ចឹមពី៣-៥ក្បាល។ ពួកគាត់អាចលក់ជ្រូករស់បានតំលៃ ៩.០០០រៀល ក្នុងមួយគីឡូក្រាម ឱ្យទៅឈ្មួញកណ្តាលដែលចូលមកទិញដល់ផ្ទះ។ ចំពោះមាន់ក៏ជាប្រភពផ្តល់ចំណូលមួយ សំខាន់ ហើយងាយស្រួលក្នុងការចិញ្ចឹមទៀតផង ដោយមិនចាំបាច់ចំណាយច្រើនក្នុងការផ្តល់ចំណីនិងថែទាំ ហើយពួកគាត់អាចលក់មាន់បានក្នុង១គីឡូក្រាមតម្លៃ ១០០០០-១២០០០រៀល។

## វិបត្តិដែលធ្វើអោយលទ្ធភាពទិញដូររបស់គ្រួសារធ្លាក់ចុះ

**១៦៥.** នៅក្នុងសហគមន៍ ដែលក្រុមការងារបានចុះធ្វើការអង្កេត បានបង្ហាញអោយឃើញអំពីរូបភាពនៃវិបត្តិដែលកើតមានឡើងនៅក្នុងសហគមន៍ទាំងនេះហាក់ដូចជា មានលក្ខណៈខុសគ្នាទៅនឹងតំបន់ភូមិភាគកណ្តាលនៃប្រទេស។ ករណីអាសន្នដែលកើតមានចំពោះសហគមន៍ទាំងនោះមានដូចជាៈ

- ការធ្វើស្រែចំការតាមបែបបុរាណគឺធ្វើស្រែប្រវាស់មេឃ ជាហេតុដែលធ្វើឱ្យប្រជាពលរដ្ឋប្រមាណ ៤០ភាគរយហូបមិនគ្រប់គ្រាន់ខ្វះស្បៀងក្នុងរយៈពេល២-៦ខែ។
- ដីធ្វើស្រែមានតិច (ស្ថានភាពដី) ធ្វើតែស្រូវមួយមុខមិនបានផ្លាស់ប្តូរមុខដំណាំ ហើយទាញយកផលតែពីដី ដោយមិនបានដាក់ជីថែទាំដី ទើបធ្វើឱ្យដីកាន់តែខ្វះជីជាតិទៅៗ។ ម្យ៉ាងទៀតចំពោះផលដំណាំដែលដាំបានដូចជា ខ្នុរ ធូរេន សៅម៉ាវ ដូងទុំ មិនអាចនាំទៅលក់ទីផ្សារក្រៅតំបន់បាន។
- ចំណែកឯបញ្ហាសុខភាពក៏នៅតែជាបញ្ហាចោទមួយដ៏សំខាន់ ដែលប្រជាជននៅតំបន់នេះកំពុងតែប្រឈមមុខដោយសារសេវាសុខភាពនៅមានកំរិតនៅឡើយ។ ក្នុងករណីមានសមាជិកណាម្នាក់ធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរត្រូវបញ្ជូនទៅមន្ទីរពេទ្យបង្អែកស្រែអំបិលឬទៅភ្នំពេញ។ ហើយទន្ទឹមនឹងនោះដែរ ដើម្បីដោះស្រាយរាល់វិបត្តិទាំងនោះពួកគាត់បានប្រើគ្រប់មធ្យោបាយទាំងអស់ ទៅតាមលទ្ធភាពដែលអាចធ្វើទៅបាន ដូចជាខ្ចីបុលពីអ្នកដទៃ ដាក់ស្រែបញ្ចាំ ចងការប្រាក់ និងលក់ស្រូវ អង្ករ គោ ក្របី ជាដើម។ ទាំងនេះជាយុទ្ធសាស្ត្រមួយដើម្បីដោះទ័លនៅពេលដែលជួបប្រទះនូវវិបត្តិសេដ្ឋកិច្ចក្នុងគ្រួសារ។

## សហគមន៍ព្រៃឈើ

**១៦៦.** ការសិក្សាអង្កេតបានបង្ហាញអោយឃើញថា នៅឃុំថ្មដូនពៅ និងឃុំជំនាប់ ពុំមានព្រៃសហគមន៍ទេ ប៉ុន្តែមានតំបន់ទុកសំរាប់ឱ្យប្រជាជនប្រើប្រាស់ក្រៅពីនោះជាតំបន់ ព្រៃការពារដោយអង្គការសង្គ្រោះសត្វព្រៃ

Draft

SCW នៅឃុំជីខលើពុំមាន ដីព្រៃសហគមន៍សំរាប់ ជាប្រយោជន៍ដល់ប្រជាពលរដ្ឋប្រើប្រាស់នៅឡើយ មានតែអង្គការ Wild Aids មួយ ជាអ្នកអភិរក្សសត្វព្រៃ និងព្រៃឈើប៉ុណ្ណោះ ។

**តំបន់គ្រប់គ្រងពិសេស**

**១៦៧.** តាមការសិក្សានិងសាកសួរផ្ទាល់មាត់បានបានឱ្យដឹងថា នៅឃុំថ្មដូនពៅ និងឃុំជំនាប់មានព្រៃអារក្សឬព្រៃតំណមចំនួន៥កន្លែង១តាដូនធំ ២.តាលួង ៣.តាងាម ៤.តាកាំ ៥.តាគោហា ដែលមានទំហំពី២-៣ហិតតាប៉ុណ្ណោះ ។ ឃុំថ្មដូនពៅមានព្រៃអ្នកតា និងព្រៃកប់ខ្មោចក្បែរភូមិចំនួន៣កន្លែង ក្រៅពីនោះក៏នៅមានតំបន់ទេសចរណ៍មួយចំនួនទៀតដូចជា ឆាយតាហ៊ីង ឆាយអារ៉ែង នៅតាមដងស្ទឹងអារ៉ែងក្នុងឃុំ តំបន់ត្រីនាគ និងតំបន់ក្រពើភ្នំ ។ ចំណែកឯនៅក្នុងឃុំជីខលើមិនមានតំបន់គ្រប់គ្រង ពិសេសទេ មានតែព្រៃតំណមអ្នកតាជដែក (ទំហំ២០ម យ ៥០ម) ដែលប្រជាជនមានជំនឿ តែងតែទៅធ្វើការបន់ស្រន់នៅពេលមានសមាជិកគ្រួសារឈឺស្កាត់ រឺពេលបាត់គោក្របី (ពតិមានបានពីលោក គង់ ណារិន អ្នកភូមិត្រពាំងកណ្តាល) ។

**ផលប៉ះពាល់នៃការអនុវត្តគំរោងអាជីវកម្មរ៉ែ ទៅលើជីវភាពរស់នៅរបស់សហគមន៍ និងការទទួលយករបស់មូលដ្ឋានចំពោះគំរោងអភិវឌ្ឍន៍ :**

យោងលើលទ្ធផលនៃការសិក្សាពិគ្រោះយោបល់ជាមួយថ្នាក់ដឹកនាំខេត្ត ស្រុក មន្ទីរ/ស្ថាប័ន ឃុំ ភូមិ និងប្រជាជនសហគមន៍ដែលពាក់ព័ន្ធ បានបង្ហាញនូវទស្សនៈយល់ដឹងពីរផ្សេងពីគ្នា:

**១៦៨.** ថ្នាក់ដឹកនាំខេត្ត ស្រុក មន្ទីរ/ស្ថាប័នពាក់ព័ន្ធ: ក្នុងករណីដែលរាជរដ្ឋាភិបាលធ្វើការប្រទានសិទ្ធិអោយក្រុមហ៊ុនធ្វើអាជីវកម្មយករ៉ែ នោះនឹងនាំមកនូវផលប្រយោជន៍ពហុវិជ្ជមានច្រើនយ៉ាង ទាំងលើវិស័យសេដ្ឋកិច្ច សង្គម និងបរិស្ថាន ។ ទោះបីជាពួកគាត់មិនអាចផ្តល់ព័តិមានលំអិតពាក់ព័ន្ធនឹងផលប្រយោជន៍ទាំងនេះក្តី តែពួកគាត់បានសំដែងសេចក្តីបារម្ភអំពីការធ្លាក់ចុះ និងបន្តបាត់បង់ធនធានព្រៃឈើដោយសារការទន្ទ្រានយកដី ធ្លីធ្វើកម្មសិទ្ធិតាមគ្រប់រូបភាពតូចធំ និងសកម្មភាពប្រមូលផលព្រៃឈើដែលបាននឹងកំពុងបន្តយ៉ាងអានាធិបតេយ្យក្នុងរូបភាពឆ្នក់លួចលាក់ ។

**១៦៩.** ជាការពិតណាស់ដែលថាការអភិវឌ្ឍន៍តែងតែមានចំណុចអវិជ្ជមាន និងការខ្វែងគំនិតគ្នារវាងវិនិយោគិនជាមួយអាជ្ញាធរនិងសហគមន៍មូលដ្ឋាន ឬរវាងវិនិយោគិននិងអាជ្ញាធរ ជាមួយអង្គការសង្គមស៊ីវិល និងសហគមន៍មូលដ្ឋាន ទៅលើផលប្រយោជន៍រួមមួយដែលទាំងអស់គ្នាមានសិទ្ធិក្នុងការទទួលបាន ប៉ុន្តែទិសដៅនិងគោលបំណងរួមរបស់ពួកយើង គឺសំដៅធ្វើយ៉ាងណាដើម្បីទទួលបាននូវការអភិវឌ្ឍន៍នៅកម្ពុជាមួយដែលធានាបាននូវកំណើននិងការអភិវឌ្ឍន៍ ជាពិសេសសម្រាប់ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជាយុទ្ធសាស្រ្ត ដែលក្នុងនោះត្រូវពង្រឹងនិងលើកកំពស់ជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន ក្នុងក្របខ័ណ្ឌមួយដែលមានលក្ខណៈអាចទទួលយកបានទាំងផ្នែកសង្គម-បរិស្ថាន និងមានប្រសិទ្ធិភាពសេដ្ឋកិច្ច ។

១៧០. ជាដំបូង ដោយសារពួកគាត់នៅមូលដ្ឋាន មិនទាន់បានយល់ច្បាស់ពីផលប្រយោជន៍ដែលនឹងត្រូវទទួលបានមក វិញពីការដែលរាជរដ្ឋាភិបាលប្រទានដីសម្បទានសេដ្ឋកិច្ចដល់ក្រុមហ៊ុន ដើម្បីក្រុមហ៊ុនចូលមកធ្វើការវិនិយោគ ពួកគាត់មានការចង្អៀតចង្អល់ជាខ្លាំង ពីព្រោះពួកគាត់បារម្ភណ៍ខ្លាចក្រែងក្រុមហ៊ុននោះមកយកដីរបស់ពួកគាត់ ដោយកន្លងមកមានក្រុមហ៊ុនមួយមិនបានអនុវត្តន៍សមស្របទៅតាមគោលការណ៍នៃដីសម្បទានសេដ្ឋកិច្ច ធ្វើ ឱ្យប្រជាពលរដ្ឋមានការថ្នាំងថ្នាក់ ហើយយល់ថាការអភិវឌ្ឍន៍របស់ក្រុមហ៊ុនមិនបានធ្វើឱ្យពួកគាត់ទទួលបាន ផលប្រយោជន៏អ្វីសោះ ក្រៅពីពួកគាត់ត្រូវបាត់បង់ដីរបស់ខ្លួនទៀតផង ។ ពួកគាត់បានលើកឡើងថាជួនកាល នៅឆ្នាំខ្លះពួកគាត់ខ្វះស្បៀងរហូតដល់ទៅ៥ខែ ដើម្បីបំពេញការខ្វះខាត គឺពួកគាត់អាចចូលព្រៃទាញយកផល ពីអនុផលព្រៃឈើបាន ដូចជា អារឈើមូល កូនឈើ ឈើក្រាក់ អុស រកវល្លិ៍ វាយផ្ដៅ ដងជ័រទឹក បេះផ្សិតឈើ បេះផ្លែឈើ បេះស្លឹកព្រិច បន្លែផ្អែម កាប់ឬស្សី រកទំពាំង និងការបរបាញ់សត្វជាដើម ។ ពិសេសជាងនេះទៅទៀត តំណាងប្រជាជនបានលើកឡើងពីគ្រោះថ្នាក់ដែលបង្កដោយការជីកយករ៉ែ ពីអណ្ដូងរ៉ែដែលមានជំរៅជ្រៅ និងការធ្វើអោយបាត់បង់លំនឹងបរិស្ថានក្នុងតំបន់ ដែលវានឹងនាំអោយជីវភាពរបស់ពួកគាត់ជួបប្រទះនឹងការ លំបាកនៅពេលអនាគត ។

១៧១. ប៉ុន្តែ បន្ទាប់ពីបានស្ដាប់ការពន្យល់អំពីទិសដៅអភិវឌ្ឍន៏ តាមគំរោងស្នើសុំដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន និងការបកស្រាយអោយពួកគាត់បានយល់អំពីអន្តរកម្មរវាងភាពក្រីក្រ និងសភាពមិនអំណោយផលរបស់ធនធានធម្មជាតិដែលពួកគាត់បានកំពុងនឹងបន្តអាស្រ័យក្នុងអនាគត ជាពិសេសអំពីគោលការណ៏ និងនិតិវិធីក្នុងការផ្ដល់ដីសម្បទានសេដ្ឋកិច្ចដល់ក្រុមហ៊ុន និងផលប្រយោជន៏ដែលប្រជាពលរដ្ឋនឹងទទួលបានមកវិញ ពិសេសគឺគោលការណ៏ដោះដូរនូវដីទាំងឡាយណាដែលពាក់ព័ន្ធជារបស់ប្រជាពលរដ្ឋ ដោយថែមទាំងមានរក្សាដែនដីបំរុងសំរាប់កំណើនចំនួនប្រជាជនក្នុងពេលអនាគត តំណាងឱ្យប្រជាជនរស់នៅឃុំថ្មដូនពៅ ឃុំជំនាប់ និងឃុំជីខលើ ទាំងអស់ (រូបភាពក្នុងឧបសម្ព័ន្ធ៩-២) មានសេចក្ដីសោមនស្សរីករាយ នឹងទទួលយកគំរោងធ្វើអាជីវកម្មយករ៉ែរបស់ក្រុមហ៊ុន ដោយគាត់បានយល់អំពីផលប៉ះពាល់ពហុវិជ្ជមានរបស់គំរោងអភិឌ្ឍន៏ ដែលអាចនាំមកនូវការកែលំអ-លើកកំពស់កំរិតជីវភាពរបស់ប្រជាជនក្នុងសហគមន៏ តាមរយៈការផ្ដល់នូវឱកាសការងារដល់យុវជន-យុវនារី ឬសមាជិកគ្រួសារដែលអាចបំរើការអោយគំរោងអភិវឌ្ឍន៏នេះ បានរួមចំណែកក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធ មូលដ្ឋាន-ពង្រឹងប្រព័ន្ធសេវាសាធារណៈរបស់ស្រុក (ផ្លូវលំជនបទ សេវាកម្មសុខភាព អណ្ដូងទឹកស្អាត សាលា រៀន) ពង្រឹងនិងពង្រីកទំនាក់ទំនងអោយកាន់តែទូលាយរវាងសហគមន៏មូលដ្ឋានជាមួយនិងសង្គមខាងក្រៅ ដែលជំរុញអោយមានអន្តរកម្មវិជ្ជមានទៅ លើចរន្តសេដ្ឋកិច្ចសហគមន៏តាមរយៈការកើនឡើងនូវសេចក្ដីត្រូវការ និងការផ្គត់ផ្គង់ ដោយពួកគាត់ទទូចហើយទទូចទៀត សំណូមពរធ្វើយ៉ាងណាកុំឱ្យបាត់បង់ ឬប៉ះពាល់ដល់ផល ប្រយោជន៏ប្រជាពលរដ្ឋ និងពិសេសគឺជួយធ្វើការអភិវឌ្ឍន៏ភូមិឃុំរបស់គាត់ផង ។

Draft

១៧២. ក្នុងឱកាសចូលរួមពិគ្រោះយោបល់ បងប្អូនតំណាងអោយប្រជាជនក្នុងស្រុក ឃុំ ភូមិសហគមន៍ទាំងមូល បានមានមតិ និងសំណូមពរដូចខាងក្រោម:

- លោក **សៀវ សាបាន** អភិបាលរងស្រុកថ្មបាំង : បើពិនិត្យមើលក្នុងផែនទីស្នើសុំដីរបស់ក្រុមហ៊ុនសំណង់រ៉ែជាប់ត្រឹមព្រំប្រទល់ឃុំជំនាប់ និងឃុំថ្មដូនពៅ ចំណែកឯឃុំប្រឡាយនៅឆ្ងាយពីទីតាំងនេះដូនេះ មានតែអស់លោកខាងផ្នែកវាយតំលៃហេតុប៉ះពាល់បរិស្ថានចុះទៅដល់ឃុំផ្ទាល់ជួបជាមួយមេឃុំដើម្បីសាកសួរពត៌មាននិងបានដឹងពីទំហំនៃការប៉ះពាល់ប៉ុណ្ណោះ ។ ចំពោះខ្ញុំជាអាជ្ញាធរស្រុកប្រសិនបើខាងក្រុមការងារចុះទៅសិក្សាទៅឃើញថា មិនពាក់ពន្ធ័ជាមួយនឹងផលប្រយោជន៍របស់ប្រជាពលរដ្ឋទេនោះ វាជាការល្អប្រសើរ ហើយបើមានក្រុមហ៊ុនចូលមកវិនិយោគនៅតំបន់នេះមែននោះខ្ញុំយល់ថាវាជាមោទនភាពរបស់ស្រុកថ្មបាំងយើង ។ ជាចុងក្រោយ សូមសំណូមពរដល់ក្រុមហ៊ុនវិនិយោគសំណង់រ៉ែត្បូងថ្ម ជួយអភិវឌ្ឍន៏ផ្លូវថ្នល់ផង ពីព្រោះផ្លូវចាប់ពីផ្លូវបែកចេញពីថ្នល់ជាតិចូលមកស្រុកថ្មបាំងនិងពីស្រុកថ្មបាំងទៅកាន់ឃុំនានា ជាពិសេសផ្លូវពីស្រុកទៅកាន់ឃុំថ្មដូនពៅ និងឃុំជំនាប់ និងឃុំប្រឡាយមានការលំបាកខ្លាំងណាស់ លើសពីនេះទៀត មានមណ្ឌលសុខភាព និងសាលារៀនអណ្តូងទឹក ។

- លោក **ឈៀក គីមសេង** ក្រុមប្រឹក្សាស្រុកថ្មបាំង : ចំពោះក្រុមហ៊ុនដែលចូលមកវិនិយោគនៅក្នុងស្រុកថ្មបាំង តាមទស្សនៈរបស់ខ្ញុំផ្ទាល់ វាជាការល្អ ពីព្រោះតំបន់យើងជាតំបន់ដាច់ស្រយាលផ្លូវធ្វើដំណើរមានការលំបាក បើមានក្រុមហ៊ុនចូលមកអភិវឌ្ឍន៏មែននោះសូមសំណូមពរឱ្យជួយអភិវឌ្ឍន៏ផ្លូវទៅកាន់ភូមិឃុំ ដូចអស់លោកអញ្ជើញទៅឃុំនោះដឹងហើយ ពុំមានស្ពានឆ្លងអូរជាច្រើនកន្លែង ។ ចំពោះការប៉ះពាល់ដល់ប្រជាពលរដ្ឋដូចជាមិនប៉ះពាល់ទេបើតាមពិនិត្យទៅលើផែនទី ពីព្រោះប្រជាជននៅឃុំទាំងពីរប្រជាជនប្រមាណ១៨០គ្រួសារតែប៉ុណ្ណោះ ដីគាត់នៅទូលាយ និងសំបូរដីជាតិគាត់រកតែក្បែរភូមិរបស់ពួកគាត់ អាចមានប្រជាជនតិចតួចទៅរកអនុផលព្រៃឈើនៅឆ្ងាយនោះ ។

- លោក **គួយ ផុន** មេឃុំជំនាប់ : ទីតាំងដែលក្រុមហ៊ុន ស្វែងរករ៉ែវាស្ថិតនៅឆ្ងាយពីតំបន់ដែលប្រជាពលរដ្ឋក្នុងឃុំរបស់ខ្ញុំរស់នៅ តែវាអាចនៅជិតតំបន់ស្រែចំការគាត់ ពីព្រោះពួកគាត់ទៅធ្វើឆ្ងាយៗពីភូមិណាស់ដូចក្មួយដឹងស្រាប់ហើយតំបន់ភ្នំវាមិនដូចតំបន់ទំនាបកណ្តាលដែលមានដីរាបស្មើនោះទេ ឱ្យតែកន្លែងណាមានទឹកដក់គាត់ទៅធ្វើកន្លែងនោះហើយ តែភាគច្រើនសំបូរតែចំការទេមិនសូវមានស្រែទេ។ ប្រសិនបើក្រុមហ៊ុនគេចូលមកធ្វើកន្លែងនេះសូមជៀសវាងការប៉ះពាល់ដល់ទឹកសំរាប់មនុស្សនិងសត្វផឹក ជាពិសេសវាលស្មៅសំរាប់សត្វ ព្រោះកាលមានរោងចក្រតែងតែមានជាតិពុលចេញពីរោងចក្រ ។ ជាសំណូមពរសូមឱ្យក្រុមហ៊ុនជួយធ្វើផ្លូវ សង់សាលារៀន ។



Draft

- លោក **ឆាយ វុធ** មេឃុំជីខលើ : បើនិយាយពីតំបន់រុករករ៉ែវាស្ថិតនៅក្នុងទឹកដីឃុំជីខលើមែន តែប្រជាពលរដ្ឋឃុំជីខលើមិនពាក់ពន្ធ័តំបន់គំរោងនោះទេ .ប៉ុន្តែនៅពេលដែលក្រុមហ៊ុនដំណើរការវាអាចជួបនូវបញ្ហាអ្វី យើងមិនអាចដឹងបានជាមុនទេនោះវាអាស្រ័យលើអ្នកជំនាញបច្ចេកទេសទៅចុះ ។

Draft